# ព្រះវិហារវត្តសំសមី

វត្តសំសមី[៧] ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ បើផ្អែកតាមសារបានវត្ត ទីអារាមនេះចាប់ផ្តើមកកើតឡើងក្នុងឆ្នាំ១៩១៩ នៅប្រឞបដងទន្លេមេគង្គ។ រីឯព្រះវិហារចាប់ផ្តើមកសាងនៅក្នុងឆ្នាំ១៩៣១ រហូតហើយរួចរាល់ជាស្ថាពរបញ្ចុះសីមាធ្វេងក្នុងឆ្នាំ១៩៤៤ ក្រោមព្រះរាជវត្តមាន **សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត សម្តេចព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ** និងព្រះរាជាធិបតីដ៏ឧត្តុង្គឧត្តម **ព្រះបរមរតនកោដ្ឋ**។ ប៉ុន្តែគំនូរក្នុងព្រះវិហារគូរនៅឆ្នាំ១៩៦៨ ដែលមានគំនូរមួយផ្ទាំងគូរភ្ជាប់នឹងព្រះធាយាលក្ខណ៍ព្រះអង្គក្នុងផ្នែកមួយនៃពុទ្ធប្រវត្តិ។

ជាការពិត គិតមកដល់បច្ចុប្បន្ន ព្រះវិហារវត្តសំសមីមានអាយុកាលជិត១០០ឆ្នាំ។ ប៉ុន្តែគេមើលឃើញថា ព្រះវិហារនេះគឺជាសំណង់មានលក្ខណៈរឹងមាំជាងព្រះវិហារតាមបណ្តាវត្តផ្សេងៗ ដែលកសាងឡើងក្នុងសម័យកាលប្រហាក់ប្រហែលគ្នា។ ព្រះវិហារនេះកសាងអំពីថ្ម លើខឿនពីរថ្នាក់ មានជញ្ជាំងខ្ពស់ស្រឡះ ដំបូលប្រក់ក្បឿង និងបំពាក់ជហ្វា៤។ ជញ្ជាំង និងហោជាងព្រះវិហារ លាបពណ៌ផ្កាឈូកស្រាល ហើយមុនឆ្នាំ២០១២ គេសង្កេតឃើញថា រចនាសម្ព័ន្ធដំបូលព្រះវិហារមានការបាក់បែក លេចធ្លុះដោយអន្ទើ (រូបលេខ១-២)។ ប៉ុន្តែក្រោយមក រចនាសម្ព័ន្ធសំខាន់ៗ និងគ្រឿងបង្គុំខ្លះនៃផ្នែកដំបូលបានជួសជុលកែលម្អយ៉ាងប្រសើរដូចឃើញសព្វថ្ងៃ (រូបលេខ៣)។




*រូបលេខ១-២ ព្រះវិហារវត្តសំសមីមុនជួសជុល (ប្រភព៖ ប៉ែន វិបុល, ២០០៨)*

[៧] ក្នុងកម្ពុជសុរិយា ឆ្នាំទី១៦ លេខ៦ ឆ្នាំ១៩៤៤ សរសេរ "សាំងសមី" ឯពាក្យខ្លះនិយាយថា "វត្តសង់សាថ្មី"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៣ ព្រះវិហារវត្តសំសមីក្រោយជួសជុលរួច (មើលពីជ្រុងអាគ្នេយ៍)

ដូចបានបញ្ជាក់មកខាងដើម ព្រះវិហារវត្តសំសមីសង់នៅលើខឿនពីរថ្នាក់។ ខឿនថ្នាក់ទី១ ខ័ណ្ឌព័ទ្ធដោយសួនផ្កា និងរបងដែក ដែលទុកច្រកចូលតាមតាមទិសទាំងបួន។ ខឿនថ្នាក់ទី២ មានកម្ពស់ប្រហែលជាង១ម៉ែត្រ មានបង្កាន់ដៃថ្មជុំវិញត្រឹមសសរបាំងសាច ដោយមានជណ្តើរឡើងតែទិសខាងកើត និងទិសខាងលិចប៉ុណ្ណោះ។ ព្រះវិហារនេះ ជាទម្រង់វិហារបុរាណដែលសង់ពង្រីកខ្នាត ឱ្យទូលាយ និងស្រឡះ ដោយមានទ្វារធំៗបីនៅទិសខាងកើតនិងខាងលិច និងទ្វារម្ខាងពីរនៅទិសខាងត្បូង និងខាងជើង ព្រមទាំងបង្អួចម្ខាង៦ នៅលើជញ្ជាំងចំហៀងទាំងពីរ (រូបលេខ២៤)។



រូបលេខ២៤-៦ ព្រះវិហារវត្តសំសមីមើលពីមុខ និងចំហៀង (រូបថត៖ ធី ដា, **AMS Central**)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

រីឯការលម្អផ្សេងៗផ្នែកខាងក្រៅជញ្ជាំងព្រះវិហារ គេឃើញមានតែនៅលើស៊ុមទ្វារ-បង្អួច និងនៅលើក្បាលសសរជុំវិញបាំងសាច។ នៅលើស៊ុមទ្វារ និងបង្អួច គឺជាក្បាច់ពុម្ពស៊ីម៉ងត៍ដែលគេឆ្លាក់ជាក្បាច់អង្គរ បំបែកជុំវិញរូបព្រះវិស្ណុជិះគ្រុឌ (រូបលេខ២៧)។ រីឯនៅតាមក្បាលសសរជុំវិញបាំងសាច លម្អដោយទេទេទយរូបគ្រុឌ មានស្លាបឆ្លាក់ជាក្បាច់ភ្ញីទេសទ្រវេងស្បូវ (រូបលេខ២៨)។ ចំណែកឯហោជាងព្រះវិហារនេះ រចនាលម្អដោយក្បាច់ដូចគ្នាទាំងសងខាង ពោលគឺឆ្លាក់ក្បាច់ភ្ញីទេសលាយជុំវិញរូបផ្ចិតចាមរតម្កល់នៅលើជើងពានដែលមានពន្លឺរង្សីនៅកំពូល និងឆ័ត្ររួតមួយគូអមសងខាង (រូបលេខ២៩)។



រូបលេខ២៧ ក្បាច់លម្អស៊ុមទ្វារ-បង្អួច



រូបលេខ២៨ ទេទេទយរូបគ្រុឌលម្អលើក្បាលសសរ



រូបលេខ២៩ ក្បាច់លម្អលើហោជាងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះខាងក្នុងព្រះវិហារ មានសសរបេតុងមូលធំៗពីរជួររត់អមសងខាងល្វែងគ្រឹះ ប្រកបដោយគំនូរ និងក្បាច់លម្អយ៉ាងវិចិត្រក្រៃលែង ដោយនៅតាមគល់សសរគេលម្អរូបព្រះកាលព័ទ្ធជុំវិញ (រូបលេខ១០)។ ប៉ុន្តែដើមឡើយផ្ទៃសសរទាំងអស់នោះ ពីក្រោមដល់លើពុំមានគំនូរ និងក្បាច់លម្អឡើយ។ ក្បាច់ក្បូរលើសសរទាំងនោះ គូរឡើងដំណាលគ្នានឹងការគូរគំនូរទូទៅលើផ្ទៃជញ្ជាំង និងពិតានដែរ ពោលគឺក្នុងរវាងឆ្នាំ១៩៦៧-១៩៦៨។ លើសសរខ្លះមានជារូបគ្រុឌត្រដាងស្លាប ហើយលើសសរខ្លះទៀតគឺជារូបកិន្នរគូរលាយនឹងក្បាច់ផ្សេងៗផងក៏មាន (រូបលេខ១១-១២)។



រូបលេខ១០ ផ្នែកខាងក្នុងព្រះវិហារ



រូបលេខ១១-១២ រូបកិន្នរ និងគ្រុឌលម្អសសរ

ព្រះជីវ៍នៃព្រះវិហារវត្តសំសមីនេះ គេកសាងតម្កល់លើបល្ល័ង្កខ្ពស់ថ្នាក់ៗ មានផ្កាឈូកនៅខាងលើ (រូបលេខ១៣)។ ព្រះបដិមាកសាងក្នុងកាយវិការផ្ចាញ់មារ ទ្រង់ក្អែនព្រះហត្ថស្ដាំដាក់លើព្រះបាទសំយ៉ុងទៅដី ដែលខ្លះហៅ ថា"យកព្រះធរណីជាសាក្សី" ដ្បិតកាលព្រះអង្គត្រាស់ដឹង មានមារមកដណ្ដើមបល្ល័ង្ករត្ននោះ។[1] បើយោងតាមឯកសារឱ្យដឹងថា ព្រះជីវ៍ធំនេះ ជាសទ្ធារបស់សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកគណៈមហានិកាយបានកសាង ដោយមានលាយចម្រុះលោហធាតុ និងរតនវត្ថុច្រើនយ៉ាងដូចជា ស្ពាន់ លង្ហិន ទង់ដែង ទង់ហ៊្វា ប្រាក់ មាស ដែលជាងវិចិត្ររចនាឱ្យមានសម្បុរលើបរលោង ហាក់ដូចបញ្ចេញរស្មីប្រាំមួយពណ៌។[2]

[1] ព្រាប ចាន់ម៉ារ៉ា ២០១៥: ២៤-៣០

[2] គុយ សូត្រ ១៩៤៤: ៣៣៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ១៣ ព្រះជីវិតម្កល់ក្នុងព្រះវិហារវត្តសំសមីសព្វថ្ងៃ*

ដោយឡែកគំនូរនៃព្រះវិហារនេះ  គឺបានបញ្ជាក់មកខាងលើស្រេចថាចាប់ផ្តើមគូរក្រោយព្រះវិហារបញ្ចុះសីមារួចជាង២០ឆ្នាំ ដោយមានជាងគំនូរពីខេត្តកំពង់ធំឈ្មោះ ម៉ែន សារឿន។ ចំពោះលក្ខណៈនៃការរៀបចំគំនូរខាងក្នុងព្រះវិហារនេះ គឺមានគំនូរពីរជួរលើជញ្ជាំងជុំវិញ និងគំនូរជាផ្ទាំងធំៗលើពិតាន។ ជាទៅទៅគេសង្កេតឃើញថា ចាប់ពីត្រឹមជួរខាងលើនៃជញ្ជាំងរហូតដល់ផ្ទៃពិតាន គេគូរបង្ហាញឈុតផ្សេងៗចម្រុះគ្នាទាំងរឿងពុទ្ធប្រវត្តិ និងរឿងក្នុងជាតកនានាដូចជា នាងបដាចារ សុមេធតាបស និងព្រះពុទ្ធប្រាំព្រះអង្គជាដើម (រូបលេខ១៤-១៦)។





*រូបលេខ១៤-១៦ គំនូរខ្វះគូរនៅលើពិតានដូចជា នាងបដាចារ សុមេធតាបស និងព្រះប្រាំព្រះអង្គ...*

អត្ថបទដោយ៖  ហៀន សុវណ្ណមរកត

គំនូរលើជញ្ជាំងមានពីរជួរ គឺជួរខាងលើជារឿងពុទ្ធប្រវត្តិចាប់ផ្ដើមពីទ្រង់ប្រសូត្រ រហូតបរិនិព្វាន។ គំនូរជួរខាងក្រោមមានខ្លឹមសាររឿងចម្រុះដូចជា រឿងជាតក ការធ្វើទារុណកម្មពួកសត្វនរក តួអង្គក្នុងរឿងរាមកេរ្តិ៍ ទេវតាប្រចាំខែឆ្នាំទាំង១២ និងរូបទេពនិករផ្សេងៗ (រូបលេខ១៧-១៩)។ ប៉ុន្តែក្នុងបណ្ដារូបនៃរឿងពុទ្ធប្រវត្តិលើជញ្ជាំងទាំងអស់ គេសង្កេតឃើញត្រង់ផ្ទាំងចែកព្រះបរមសារីរិកធាតុព្រះពុទ្ធ (រូបលេខ២០) មានរូបតួយុវក្សត្រមួយព្រះអង្គ ទ្រង់ព្រះពស្ត្រក្បិនពណ៌ផ្កាឈូក ព្រះភូសាកុតកត្រង់ពណ៌ស ទ្រង់គ្រឿងព្រះឥស្សរិយយស ហើយយាងទ្រព្រះកោដ្ឋមាសមួយផង (រូបលេខ២១)។ ក្នុងរូបនេះ អ្នកខ្លះយល់ថាគឺជាព្រះឆាយាលក្ខណ៍ **ព្រះបរមរតនកោដ្ឋ**។





រូបលេខ១៧-១៩ គំនូររឿងជាតក រូបទេវាប្រចាំឆ្នាំ តួអង្គក្នុងទេពកថា និងការធ្វើទារុណកម្មសត្វនរក




រូបលេខ២០-២១ ពិធីចែកព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជារួមមក ព្រះវិហារវត្តសំសមី ជាសំណង់ដែលបង្ហាញឱ្យឃើញពីទឹកដៃសិល្បៈដ៏ល្អមួយ ឆ្លងកាត់តាំងពីចុងសម័យអាណាព្យាបាលបារាំង សម័យសង្គមរាស្ត្រនិយម រហូតដល់បច្ចុប្បន្ន។ មិនតែប៉ុណ្ណោះ តាមរយៈឯកសារក៏បានបង្ហាញថាព្រះវិហារនេះក៏ជាចំណែកអានិសង្សរបស់សម្ដេចព្រះសង្ឃរាជ ព្រះសង្ឃគ្រប់ជាន់ថ្នាក់ និងជាពិសេសគឺព្រះរាជូបត្ថម្ភគាំទ្ររបស់ **ព្រះបរមរតនកោដ្ឋ**។ ប្រហែលប្រការចុងក្រោយនេះ ទើបជាង ២០ឆ្នាំក្រោយមក គេហាក់ដូចជាចង់រំលេចភ្ជាប់ព្រះឆាយាលក្ខណ៍ព្រះអង្គក្នុងគំនូរនៃពិធីចែកព្រះបរមសារីរិកធាតុព្រះពុទ្ធ។

## ឯកសារយោង

គុយ សូត្រ

១៩៤៤, "ពិធីបុណ្យបញ្ចុះខណ្ឌសីមានៅវត្តសាំងសមី (ព្រៃវែង)", *កម្ពុជសុរិយា*, ឆ្នាំទី១៦, លេខ៦, ទំ.៣៣២-៣៣៦, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៥, "ផ្ចាញ់មារ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ. ២៤-៣០, យសោធរ, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត